RECOVER

a consortium made by/

# ឯកសារជំនួយស្មារតី
# សម្រាប់
# គ្រូបង្គោលសហគមន៍កសិកម្ម

## ផលិតកម្មបន្លែ



ស្ថិតក្រោម គម្រោងការបង្កើតការងារដើម្បីស្តារសេដ្ឋកិច្ចជនបទក្រោយវិបត្តកូវីដ-១៩

ខ្លឹមសារក្នុងអត្ថបទនេះមិនមែនជារបស់សហភាពអឺរ៉ុបទេ

គាំទ្រដោយ សហភាពអឺរ៉ុប

Co-funded by the European Union
សហការឧបត្ថម្ភដោយ សហភាពអឺរ៉ុប

អនុវត្ត ដោយ សហគមបណ្តាញកសិករ និងធម្មជាតិ

# មាតិកា


**១. បន្លែ និង អាហាររូបបត្ថម្ភ និងវិតាមីន**

**២. ទិដ្ឋភាពនៃការដាំដំណាំបច្ចុប្បន្ន**

**៣. ធាតុផ្សំនៃការគ្រប់គ្រងដំណាំ**

៣.១ គ្រាប់ពូជដំណាំ

៣.២ ប្រតិទិនរដូវកាលដាំដុះ

៣.៣ ថ្នាលបណ្ដុះកូនដំណាំ

៣.៤ ការគ្រប់គ្រងកត្តាចង្រៃ

៣.៥ ជីកំប៉ុស្តិ៍ធម្មជាតិ

៣.៦ ថ្នាំពុលផលិតពីធម្មជាតិ

៣.៧ ការគ្រប់គ្រងទឹក

៣.៨ ការប្រមូលផល

# ១. បន្លែ និង អាហាររូបបត្ថម្ភ និងវិតាមីន

- វីតាមីនអា៖ សំរាប់ធ្វើអោយស្បែករលោងនិងមានសុខភាពល្អ ភ្នែកមើលឃើញច្បាស់ សរីរាង្គខាងក្នុងមានសុខភាពល្អ។

- វីតាមីនបេ៖ ជួយប្រពន្ធ័សរសៃប្រសាទអោយធ្វើការល្អ ជយយដល់ការលូតលាស់នៃរាងកាយ និងជួយបង្កើនថាមពល

- វីតាមីនសេ៖ ពង្រឹងប្រពន្ធ័ភាពស៊ាំរបស់រាង្គកាយទប់ទល់នឹងជំងឺផ្សេងៗ ជួយអោយឆាប់ជាសះនូវ ស្នាមដាច់និងរបួស ធ្វើអោយកោសិកាទាំងអស់មានសកម្មភាព។

- ប្រូតេអ៊ីន៖ ជួសជុលកោសកា និងជាលិកា សំរាប់បង្កើនថាមពល និងការលូតលាស់

- កាល់ស្យូម៖ សំរាប់ធ្វើអោយឆ្អឹង និងធ្មេញរឹងមាំ

- ជីវជាតិដែក៖ ដឹកនាំអុកស៊ីសែនពីសួតទៅកាន់គ្រប់កោសិកាទាំងអស់

បន្លែស្ថិតក្នុង ក្រុមអាហារការពារ



# ២. ទិដ្ឋភាពនៃការដាំដំណាំបច្ចុប្បន្ន

- ដំណាំបែបគីមីនិងថ្នាំពុល៖ ប្រើប្រាស់ថ្នាំពុលកសិកម្មនិងជីកសិកម្មជាគោលក្នុងការដាំដុះ



- ដំណាំបែបហាយដ្រូផូនិក៖ ដំណាំដោយប្រើជីគីមីទឹក (សារធាតុចិញ្ចឹមរាវ)



- ដំណាំបែបអេខ្វាផូនិក៖ ជាផលិតកម្មបន្លែជាមួយនឹងត្រី។



- ដំណាំបែបសរីរាង្គនិងបញ្ជាក់គុណភាពសរីរាង្គ៖ កំរិតក្នុងស្រុក

- ការដាំដំណាំដោយការអនុវត្តន៍កសិកម្មល្អ៖ ស្តង់ដារបស់ក្រសួងកសិកម្ម (Cam GAP)

# ៣. ធាតុផ្សំនៃការគ្រប់គ្រងដំណាំ

## តើអ្វីជាភាពជោគជ័យរបស់អ្នកដាំដំណាំ?

**កត្តាចាំបាច់៣យ៉ាងដែលអាចអោយការដាំដំណាំទទួលបានជោគជ័យគឺៈ**

- អ្នកដាំដែលមានឧបនិស្ស័យ/ចូលចិត្តការដាំដុះ



- អ្នកដាំដែលចេះជ្រើសរើសពូជល្អ, កែប្រែគុណភាពដី, មើលពេលវេលាដាំដុះសមប្រកប, ដឹងអំពីតំរូវការរបស់រុក្ខជាតិ (ត្រូវការជី ត្រូវការទឹក, ត្រូវការថែទាំ និងការពារ រួមមានការកំចាត់ស្មៅ និងសត្វល្អិតចង្រៃ)







- អ្នកដាំដែលចេះប្រមើលមើលទីផ្សារ ដាំដោយមានផែនការ មិនដាំតាមគ្នា

## ៣.១ គ្រាប់ពូជដំណាំ

### តើមានភាពខុសគ្នាយ៉ាងណារវាងពូជក្នុងស្រុក និងពូជក្រៅស្រុក?

| | ពូជទុកខ្លួនឯង | ពូជនាំចូល |
|---|---|---|
| **ចំណុចវិជ្ជមាន** | • មិនចំណាយ<br>• ដឹងពីកំរិតធន់ទ្រាំនឹងបរិស្ថានក្នុងស្រុក<br>• ដឹងអំពីការដុះលូតលាស់<br>• ដឹងអំពីគុណភាព ទិន្នផល | • ផ្តល់ទិន្នផលខ្ពស់<br>• ធន់ទ្រាំនឹងជំងឺ |
| **ចំណុចអវិជ្ជមាន** | • អាចមានលាយពូជចំរុះ<br>• អាចមានដំណុះទាប<br>• មានការជ្រើសរើស និងទុកដាក់មិនល្អ<br>• អាចមិនសូវធនទ្រាំនឹងជំងឺ | • តម្លៃថ្លៃ<br>• មិនសមស្របនឹងអាកាសធាតុក្នុងតំបន់យើង<br>• មិនអាចទុកពូជបន្ត<br>• ត្រូវទិញគេជាប្រចាំ<br>• ជ្រលក់ពណ៌សំរាប់ការពារគ្រាប់ដំណាំ |

- តើគ្រាប់ពូជល្អមានន័យយ៉ាងដូចម្តេច?

  ពូជល្អ ជាពូជដែលមានដំណុះល្អ ឬដុះច្រើន។




- **តើអ្នកបានដឹងអំពីគុណភាពពូជដោយរបៀបណា (មានគុណភាព និងគ្មានគុណភាព)?**

  ○ **ដាក់គ្រាប់ពូជត្រាំទឹក**




  ○ **ការធ្វើតេស្តដំណុះគ្រាប់៖** ការធ្វើតេស្តនេះក្នុងគោលបំណង៖

   – គ្រាប់ពូជនោះ មានដំណុះគ្រាប់ប៉ុន្មានភាគរយ (ដុះបានប៉ុន្មាន?)

   – ពន្លកគ្រាប់ដែលដុះចេញមកមានកំលាំងល្អស្មើរគ្នាដែរទេ

   – ពន្លកដែលចេញមកមានជំងឺដែរទេ (គ្រាប់ពូជមានជំងឺឬអត់)?

   – សំរេចចិត្តថា តើគួរយកពូជនោះមកធ្វើការដាំដុះដែរឬទេ?

   – តើគួរបន្ត ឬប្តូរដៃគូរដែលផ្គត់ផ្គង់ពូជ?

○ របៀបធ្វើតេស្តដំណុះគ្រាប់៖គឺអនុវត្តន៍តាមរបៀបយ៉ាងសមញ្ញខាងក្រោម៖

- យកក្រដាស់(ជក់ទឹក) ស្អាតមក ដាក់ពីលើផ្ទៃថាស រួចបាញ់ទឹកលើអោយសើមបន្តិច
- យកដង្កៀបមករោលនឹងភ្លើងអាល់កុលដើម្បីសម្លាប់មេរោគ
- យកដង្កៀបមកចាប់គ្រាប់ពូជម្តងមួយគ្រាប់ៗ រួចតំរៀបលើក្រដាស់ក្នុងទំរង់ឆ្លាស់គ្នា (៥ x ៥ជួរ, មួយជួរ៥គ្រាប់)
- ក្រាលក្រដាស់(ជក់ទឹក) លើគ្រាប់ពូជដែលបានតំរៀបរួច ហើយបាញ់ទឹកពីលើអោយសើមបន្តិច
- យកដង្កៀបរមូរក្រដាស់ចូលគ្នា រួចច្រកក្នុងថង់ស្អាតមួយ រួចចងកៅស៊ូមាត់ថង់(មិនអោយជិតណែនទេ)
- យកទៅដាក់ក្នុងបន្ទប់ដែលមានសីតុណ្ហភាពសមស្រប
- រង់ចាំរយ:ពេល ៣-៨ថ្ងៃ អាស្រ័យនឹងប្រភេទដំណាំនីមួយៗ ដើម្បីពិនិត្យមើលអាត្រាដំណុះគ្រាប់ ក៏ដូចជាស្ថានភាពសុខភាពរបស់ពន្លកគ្រាប់ រួចធ្វើការវិនិច្ឆ័យនិងសំរេចចិត្ត។

❖ 

## ○ ការផលិតពូជដោយខ្លួនឯង

គំនិតពិចារណាក្នុងដំណើរការផលិតពូជ និង ការរក្សាទុកពូជៈ

- ✓ ផលិតកម្មពូជគួរធ្វើនៅខែវិច្ឆិកា-មករា ជាពេលវេលាសមស្របល្អបំផុត
- ✓ គ្រប់កូនដំណាំដែលយកមកស្ទូង គឺមានសុខភាពល្អ
- ✓ ដីនិងជីដែលដាំដំណាំយកពូជគឺ ត្រូវបានរៀបចំយ៉ាងល្អ (រាបស្មើរ និងមានជីជាតិគ្រប់គ្រាន់)
- ✓ ចន្លោះគុម្ព និងចន្លោះរងត្រូវបានរក្សាទុកអោយធំទូលាយជាងការដាំសម្រាប់ហូបឬលក់ដូរ
- ✓ ទឹក ការថែទាំ កំចាត់កត្តាចង្រៃ ត្រូវបានអនុវត្តន៍ដោយការយកចិត្តទុកដាក់
- ✓ ដំណាំណាដែលរងការបំផ្លាញធ្ងន់ធ្ងរដោយកត្តាចង្រៃផ្សេងៗ ត្រូវកាត់ចេញ
- ✓ ផ្លែល្អៗ ថ្លោសៗ មានទំរង់ត្រឹមត្រូវ ត្រូវបានរក្សាទុកត្រឹមតែ ៣-៧ផ្លែក្នុង១ដើមតាមប្រភេទដំណាំ
- ✓ ទុកផ្លែអោយទុំល្អ និងមិនត្រូវប្រមូលផលកំឡុងពេលមានភ្លៀងឡើយ
- ✓ គ្រាប់ត្រូវបានលាងសំអាតអោយបានស្អាតល្អ
- ✓ ហាលគ្រាប់អោយបានស្ងួតល្អ (ហាលពេលព្រឹកព្រះអាទិត្យរះ រហូតដល់ម៉ោង ១០ ឬ ១១ព្រឹក)

គ្រាប់ស្ងួតត្រូវបានច្រកទុកក្នុងស្បៃក្រណាត់ ឬឧបករណ៍ស្អាត ដើម្បីរក្សាទុក។




❖

◦ **ការស្វែងយល់អំពីលក្ខខណ្ឌដំណាំ**

- ដំណាំដែលធន់នឹងការរាំងស្ងួត៖ ននោង ឃ្លោក ល្ពៅ ពពាយ ដំឡូងឈើ ឪឡឹក សណ្ដែក ត្រប ប៉ិគក់ ល្ហុង ចេក រំដេង ខ្ទាយ សាគូ
- ដំណាំដែលធន់នឹងការជាំទឹក៖ ត្រកួន ត្រាវ ក្ដាត ម្អម ជីសាំងហ៊ុម កញ្ឆែត (ភ្លៅកង្កែប)
- ដំណាំដែលធន់នឹងម្លប់៖ ជីរណា, ម្នាស់, ខ្ញី, ខ្ទឹម, រំដេង, ខ្ទាយ, រមៀត
- ដំណាំដែលត្រូវការទឹក ជី និងការថែទាំខ្ពស់៖ ស្ពៃ ផ្កាខាត់ណា ឆៃថាវ..

## ៣.២ ប្រតិទិនរដូវកាលដាំដុះ

| ល.រ | រដូវ | សីតុណ្ហភាព | កំណត់សំគាល់ |
|---|---|---|---|
| ១ | ដើមរដូវប្រាំង (វិច្ឆិកា-មករា) | 21-30 អង្សាសេ | ខែរដូវរំហើយ (ត្រសក់, ល្ពៅ, បន្លែ...) |
| ២ | **ចុងរដូវប្រាំង (កុម្ភៈ-មេសា)** | **22-36 អង្សាសេ** | **ខែប្រាំង (សំរាក) សត្វសំបូរល្អិតចង្រៃ** |
| ៣ | ដើមរដូវវស្សា (ឧសភា-កក្កដា) | 25-34 អង្សាសេ | ដើមវស្សា(ព្រួសសណ្ដែកខែ5ភ្ជួរលុបខែ7) |
| ៤ | ចុងរដូវវស្សា (សីហា-តុលា) | 21-32 អង្សាសេ | រដូវវស្សា (ធ្វើស្រែ) |

## ៣.៣ ផ្ទាលបណ្ដុះកូនដំណាំ

១. តើមានភាពខុសគ្នាបែបណាខ្លះ រវាងការដាំគ្រាប់ផ្ទាល់និងការបណ្ដុះកូនដំណាំ ទើបយកទៅដាំ?

| ការដាំគ្រាប់ផ្ទាល់ | ការស្ទូងកូនដំណាំ |
| --- | --- |
| អាចដុះ អាចមិនដុះ<br>សត្វស៊ី ឬពាំគ្រាប់<br>ដុះអត់ស្មើគ្នា<br>មិនដឹងថា មិនដុះដោយសារគ្រាប់ពូជឬ ដោយសារអ្វី? | អាចជ្រើសរើសយកតែកូនល្អៗមកស្ទូង<br>ដំណាំផ្ដល់ផលស្មើរគ្នាល្អ<br>ផ្ដល់ផលខ្ពស់ |

២. តើយើងគួរយកចិត្តទុកដាក់លើអ្វីខ្លះ ដើម្បីបណ្ដុះកូនដំណាំបានល្អ?

- ដីដែលយកមកបណ្ដុះកូនដំណាំ គឺត្រូវតែជាដីមានជីជាតិល្អ ហើយត្រូវលីងឬ ចំហុយសំលាប់មេរោគ ស្រោចទឹក ថៃទាំអោយបានល្អ។
- របៀបលាយដីសំរាប់ការដាក់បណ្ដុះគ្រាប់ដំណាំ៖
  - ដីស្រទាប់ ឬដីមានជីជាតិ៖ ១ភាគ
  - ធ្យូងអង្កាម ៖ ២ភាគ (ត្រូវត្រាំទឹក ១-២យប់ដើម្បីបំបាត់ភាពប្រៃ ហើយស្រង់ អោយស្រស់ទឹកមុននឹងយកមកលាយ)
  - ជីកំប៉ុស្ដិ៍៖ ១ភាគ។



  - របៀបធ្វើ៖ ***យកដីស្រទាប់លើ + ធ្យូង + ជីកំប៉ុស្ដិ៍*** លាយអោយសព្វល្អ រួចដាក់ ចូលក្នុងកន្ទោងបណ្ដុះ ហើយដាក់ គ្រាប់បណ្ដុះភ្លាមតែម្ដង។



## ចំណុចសំខាន់ៗ នៃការបណ្តុះកូនដំណាំ ការដកនិងការស្ទូងកូនបន្លែដែលកសិករគួរយកចិត្តទុកដាក់

| លរ. | ជំនួយស្មារតី | ហេតុផល |
|---|---|---|
| ១ | កន្លែងថ្នាលបណ្តុះកូនបន្លែះ អាចត្រូវពន្លឺព្រះអាទិត្យពេលព្រឹក និងកាត់បន្ថយ ព្រះអាទិត្យចាប់ពីម៉ោង ១០ព្រឹកតទៅ។ | ✓ ពន្លឺពេលព្រឹកល្អចំពោះកូនដំណាំ<br>✓ កំដៅធ្វើអោយស្វួត និងបំផ្លាញកូនដំណាំ |
| ២ | ថ្នាលបណ្តុះត្រូវតែរាបស្មើរល្អ | ✓ ការពារការលិចនៅផ្នែកទាប<br>✓ ការពារការស្ងួតខ្លាំងនៅផ្នែកខ្ពស់<br>✓ ការពារការហូរចេញសារធាតុចិញ្ចឹម |
| ៣ | ថ្នាលបណ្តុះមានកំពស់១០សង់ទីម៉ែត្រ | ✓ ខ្ពស់ជាងដីធម្មតា  ការពារការដក់ទឹក |
| ៤ | លាយដីសំរាប់ថ្នាលបណ្តុះកូនបន្លែអោយបានល្អ (មិនខ្សាច់ពេក មិនដីឥដ្ឋពេក)និងមានសមាស ធាតុសរីរាង្គ(ជីកំប៉ុស្ត៍) | ✓ កូនបន្លែងាយស្រួលដុះពន្លកផុតពីដី<br>✓ ងាយស្រួលដល់កូនបន្លែក្នុងការចាក់ឫស |
| ៥ | ធ្វើការឆូតជាក្រឡាចក្រង្គ (៨ជ្រុងតូចៗតាមប្រភេទបន្លែ) | ✓ ងាយស្រួលក្នុងការបេះ ឬកាត់ចេញ |
| ៦ | ដុតថ្នាលបណ្តុះ បើសិនជាមានការឆ្លងមេរោគ | ✓ ដើម្បីសំលាប់មេរោគ |
| ៧ | ដាស់ដំណេកគ្រាប់ពូជមុនពេលបណ្តុះ | ✓ ឆាប់ដុះស្មើរៗគ្នាល្អ |
| ៨ | អាយុកាលបន្លែគិតពីសាបរហូតដល់ថ្ងៃត្រូវប្រមូលផល<br>✓ បើបន្លែអាយុ១ខែ គឺត្រូវដកកូនបន្លែអាយុ ១០-13ថ្ងៃ<br>✓ បើបន្លែអាយ២ខែ គឺត្រូវដកកូនបន្លែអាយុ ១៥-២០ថ្ងៃ<br>✓ បើបន្លែអាយុ៣ ខែ គឺត្រូវដកកូនបន្លែអាយុ ២៥-៣០ថ្ងៃ | ✓ បន្លែផ្សេងគ្នា ត្រូវការពេលវេលាស្ទូងផ្សេងគ្នា<br>✓ កូនបន្លែដែលខ្ចីពេក ឬចាស់ មិនមានគុណភាព ល្អឡើយ |
| ៩ | បន្ថយការស្រោចទឹកថ្នាលបណ្តុះជាបណ្តើរៗមុនពេលស្ទូង | ✓ កាត់បន្ថយការលូតលាស់ស្លឹក និងត្រួយ<br>✓ បន្តជំរុញការលូតលាស់ឫស |
| ១០ | ដកកូនបន្លែកុំអោយដាច់ឫសច្រើន រក្សាដីអោយជាប់ឫសខ្លះ | ✓ អោយកូនបន្លែដុះលូតលាស់ក្រោយស្ទូង |
| ១១ | ស្ទូងកូនបន្លែភ្លាម ឬយ៉ាងយូរ60នាទីក្រោយដកពីថ្នាល | |
| ១២ | កុំស្ទូងកូនបន្លែជ្រៅពេក | ✓ អាចធ្វើអោយរលួយឫស ដើម ឬងាប់ |
| ១៣ | ការស្ទូងត្រូវមានគំលាតត្រឹមត្រូវតាមប្រភេទបន្លែ | ✓ មិនមានការប្រជែងឫស និងពន្លឺ<br>✓ ទទួលបានខ្យល់គ្រប់គ្រាន់ |
| ១៤ | ការដក និងការស្ទូងកូនបន្លែគួរធ្វើពេលល្ងាច | ✓ កាត់បន្ថយការសន្លប់របស់កូនបន្លែ<br>✓ កាត់បន្ថយភាពប្រថុយប្រថាននៃការសន្លប់ |





## ៣.៤ ការគ្រប់គ្រងជីជាតិដី

❖ដីមានជីវិត″ មានន័យយ៉ាងដូចម្តេចដែរ?

❖ តើដីដែលមានជីជាតិល្អ មានលក្ខណៈសំគាល់អ្វីខ្ល

❖ បុព្វហេតុដែលធ្វើអោយដីខូច?

តើកន្លងមកយើងបានធ្វើអ្វីខ្លះក្នុងការកសាងជីជាតិដី



ដីមានជីជាតិល្អ មានលក្ខណៈសំគាល់៖

- មានសំបុរក្រមៅ,
- ដីផុសល្អ/ដីធូ,
- មានស្មៅនិងរុក្ខជាតិដុះច្រើន,
- សម្បូរសត្វល្អិត,
- មិនខ្សាច់ពេកនិងមិនស្អិតពេក



## បុព្វហេតុដែលធ្វើអោយដីខូចៈ

- មិនអនុវត្តន៍ការដាំដំណាំចំរុះ ឬដំណាំឆ្លាស់
- ដុតកំទេចកំទីសរីរាង្គលើកសិដ្ឋាន (ឧទា.ដុតចំបើង, ដុតគល់ជញ្ជ្រាំង...)
- ប្រើប្រាស់ជីគីមីនិងថ្នាំពុលកសិកម្មមិនសមស្រប
- មិនបានបន្ថែមសារធាតុសរីរាង្គឬជីកំប៉ុស្តិ៍អោយដី
- មិនដាំដុះនិងមិនភ្ជួរលប់កប់ពពួកដំណាំជីបៃតងដូចជាៈ សណ្តែកបាយ, សណ្តែកសៀង..
- មិនបានគ្របដីដោយការដាំដំណាំគំរបដី និងក្រាលគ្របដី(អង្កាម, ចំបើង...)
- ភ្ជួរជ្រៅពេក (ធ្វើអោយផ្ទៃកខាងលើដែលមានសារធាតុសរីរាង្គត្រឡប់ចុះក្រោម ហើយដីដែលខ្សត់ជីជាតិត្រលប់មកផ្ទៃខាងលើវិញ)

## តើអ្វីខ្លះដែលយើងអាចធ្វើបាន ដើម្បីកសាងជីជាតិដី(សំបូរមមោក)?

| ល.រ | សកម្មភាព | ហេតុផល |
|---|---|---|
| 1 | បន្ថែមនិងបង្កើនការប្រើជីកំប៉ុស្តិ៍ ឬសារធាតុសរីរាង្គអោយដីអោយបានច្រើនតាមដែលអាចធ្វើបាន | ➢ ជួយកែលំអរសមត្ថភាពរក្សាទឹក<br>➢ ទឹកអាចជ្រាបចូលចេញ-បានល្អ<br>➢ ធ្វើអោយខ្យល់ចេញចូលបានល្អ<br>➢ ធ្វើអោយដីផុសល្អ ងាយស្រួលដល់ឬដំណាំ |
| 2 | ក្រាលគំរបដីកំទេចឈើ,អង្កាម ចំបើង, ស្រកីដូងម៉ត់ | ➢ រក្សាសំណើមក្នុងដីបានយូរ<br>➢ ផ្តល់នូវសារធាតុចិញ្ចឹមទៅដីក្រោយពេលពុកផុយ រលួយ/ |
| 3 | ដាំដំណាំគំរបដី(ពពួកសណ្តែក) | ➢ ការពារការសឹករេចរិលរបស់ដោយខ្យល់ និងទឹក |
| 4 | ដាំដំណាំចំរុះ ដំណាំឆ្លាស់ ឬដំណាំបង្វិល | ➢ កាត់បន្ថយកត្តាចង្រៃផ្សេងៗ<br>➢ រក្សាបាននូវជីជាតិដី |
| 5 | មិនដុតគល់ជញ្ជ្រាំង | ➢ រក្សាបាននូវសត្វល្អិតដែលជួយបំផុសដី |
| 6 | ភ្ជួរបំផុសដីមិនភ្ជួរត្រឡប់ដី, | ➢ ជួយអោយដីមានជីជាតិនៅស្រទាប់លើ |
| 7 | ពង្រាបដីអោយស្មើល្អ | ➢ ជួយទឹកនិងជីរត់សព្វស្មើរគ្នាល្អ |
| 8 | ការលើកភ្លឺទប់អោយបានខ្ពស់ល្អ | ➢ កាត់បន្ថយនូវការហូរច្រោះឬនាំយកជីជាតិដីទៅក្រៅចំការ |
| 9 | មិនប្រើប្រាស់ ឬកាត់បន្ថយការប្រើប្រាស់ថ្នាំពុលកសិកម្ម | ➢ រក្សាបាននូវសត្វល្អិតមានប្រយោជន៍<br>➢ រក្សាបាននូវលំនឹងអេកូឡូស៊ី<br>➢ កាត់បន្ថយឬផ្តាច់នូវផលប៉ះពាល់ដល់ដល់សុខភាពអ្នកប្រើប្រាស់និងអ្នកហូប |

# ៣.៨ ការគ្រប់គ្រងកត្តាចង្រៃ

- តើគ្រប់សត្វល្អិតទាំងអស់សុទ្ធតែចង្រៃឬ?
- សត្វល្អិតមានប្រយោជន៍ និងសត្វល្អិតចង្រៃសំគាល់ដោយរបៀបណា?
- តើអ្វីខ្លះជាគំនិតសំខាន់ៗនៅការទប់ទល់នឹងកត្តាចង្រៃ?

សត្វល្អិតមានប្រយោជន៍សំខាន់ៗមានបីប្រភេទគឺ

- ✓ **ពពួកប្រេដាទ័រ៖** ជាពពួកសត្វដែលស៊ីសត្វជាអាហារ។
- ✓ **ប៉ារ៉ាស៊ីត៖** ជាពពួកបង្កើតប៉ារ៉ាស៊ីតក្នុងខ្លួនសត្វផ្សេងទៀត។
- ✓ **ភ្នាក់ងារបង្ករោគ៖** ជាពពួកណេម៉ាតូត, វីរុស, បាក់តេរី, ផ្សិត, ប្រូតូស៊ូអា











## ៣.៥ ជីកំប៉ុស្តិ៍ធម្មជាតិ

តើសារធាតុសំខាន់ៗអ្វីខ្លះដែលដំណាំត្រូវការ? វាមាននៅឯណាខ្លះ?




# ការធ្វើជីកំប៉ុស្តិ៍ធម្មជាតិរយៈពេលខ្លី

- ចំបើង, រុក្ខជាតិស្រស់ឬស្ងួត (ស្លឹកឈើ, កំប្លោក, ត្រគៀត, កាកសំណល់ក្រោយពេលប្រមូលផល...), លាមកគោស្រស់ ឬក្រៀម, ដីស្រទាប់លើឬដីមានជីជាតិ, បើអាចបន្ថែមនូវះកន្ទក់ម៉ត់ ធ្យូងអង្កាម ឬកំទេចធ្យូងតូចៗ, កាកកាហ្វេ, ស្រកីដូងម៉ត់, សំបកម្សៅឆ្អឹង...
- ទឹក (១០លីត្រ) + ទឹកស្កររង្វ/ស្ករកាកអំពៅ (២០សេសេ) + មេជីទឹក (២០សេសេ) សម្រាប់ស្រោច។



# ជីទឹកជូលីនស៊ី (អតិសុខុមប្រាណស្មើសំយោគ)

## – គ្រឿងផ្សំ

| ល.រ | គ្រឿងផ្សំ | បរិមាណ |
|---|---|---|
| ១ | ពងមាន់ | ១ គ្រាប់ |
| ២ | ប៊ីចេង | ១ ស្លាបព្រាបាយ |
| ៣ | កាពិ ឬទឹកត្រី | ១ ស្លាបព្រាបាយ |
| ៤ | ម្សៅសំបកពងមាន់ | ១ ស្លាបព្រាបាយ |
| ៥ | ទឹកដោះគោឆៅ | ២ ស្លាបព្រាបាយ |
| ៦ | ទឹកភ្លៀង ឬទឹកបឹង | ៧ ដបទឹកសុទ្ធខ្នាត2លីត្រ |

## – របៀបធ្វើ

ដាក់គ្រឿងផ្សំទាំង៥មុខចូលគ្នា រួចកូរអោយសព្វ បន្ទាប់មកដួសល្បាយ ១ស្លាបព្រាបាយ ច្រកចូលដបទឹកដែលមានទឹកភ្លៀងឬទឹកបឹងប្រមាណជាង ១លីត្រ (ទុកចន្លោះខ្លះសំរាប់ឡើងហ្គាស) មួលបិទគំរប ហើយក្រឡុកវាថ្នមៗ រួចយកទៅហាលថ្ងៃចោល១ព្រឹកៗ រយៈពេល ៣០ថ្ងៃ ទៅ ៤០ថ្ងៃ។



## – របៀបប្រើ

ទឹកមេជីនេះ ២-៤ស្លាបព្រាខ្លី លាយជាមួយទឹកធម្មតា ១០លីត្រ បាញ់លើដំណាំ



ជូលីនស៊ី ប្រើកាពិ



ជូលីនស៊ី ប្រើទឹកត្រី

## ៣.៦ ថ្នាំពុលផលិតពីធម្មជាតិ

### សកម្មភាពរបស់ថ្នាំពុលផ្សំពីរុក្ខជាតិ ឬសរីរាង្គ

- **សកម្មភាពបណ្តេញ៖** អាចបណ្តេញសត្វល្អិតចេញពីដំណាំដោយសារក្លិន និងរសជាតិរបស់រុក្ខជាតិ។
- **សកម្មភាពប្រឆាំងនឹងការស៊ីចំណី៖** ធ្វើអោយសត្វល្អិតបន្ថយការស៊ីចំណីរហូតដល់ងាប់។
- **សកម្មភាពប្រឆាំងនឹងការផលិតពងនិងកូន៖** ធ្វើអោយសត្វល្អិតមិនហ៊ានផលិតឬបញ្ចេញពងរបស់វា។
- **សកម្មភាពប្រឆាំងនឹងការលូតលាស់និងការបង្កកំណើត៖** ធ្វើអោយសត្វល្អិតឈប់វិវដ្តនិងបន្តពូជ។
- **ប្រសិទ្ធិភាពរបស់ថ្នាំពុលរុក្ខជាតិ៖** មានជាតិពុលតិចជាង និងឆាប់បំបែកធាតុជាងថ្នាំពុលគីមី ដែលទាមទារអោយកសិករប្រើច្រើនសារ។
- **ពេលវេលាប្រើប្រាស់៖** គឺទាមទារនូវការប្រើប្រាស់នៅពេលប្រើប្រាស់នៅពេលព្រឹក ឬពេលល្ងាច
- **ភាពធន់របស់សត្វល្អិត៖** ការប្រើថ្នាំពុលរុក្ខជាតិតែមួយប្រភេទជាច្រើនដង គឺអាចធ្វើអោយសត្វល្អិតស៊ាំនិងធន់បាន។

### ប្រភេទរុក្ខជាតិដែលអាចប្រើជាថ្នាំពុល

- គួរប្រើដោយប្រុងប្រយត្ន័)
- **រុក្ខជាតិមានជាតិល្វីង៖** ឧទា. ស្តៅ, ម្រះ
- **រុក្ខជាតិមានក្លិនឆ្ងួល ៖** ឧទា. ខ្ទឹម
- **រុក្ខជាតិមានរសជាតិហិរ ៖** ឧ ទា. ម្ទេស
- **រុក្ខជាតិមានជាតិស្អិត (ជ័រច្រើន)៖** ឧទា. ល្ហុងខ្វង, រលាស់ជើងក្អាម


មើមខ្ទឹមស


ផ្លែម្រះ


ស្លឹកស្តៅ


មើមខ្ទឹមក្រហម


រមៀត


ស្លឹកថ្នាំជក់

# រូបមន្តផ្សំថ្នាំពុលពីរុក្ខជាតិ

- **រូបមន្តទោល៖** ជាការជ្រើសរើសប្រភេទរុក្ខជាតិថ្នាំពុលណាមួយតែមួយមុខ ដើម្បីយកមកចម្រាញ់ធ្វើជាថ្នាំពុលរុក្ខជាតិ ដើម្បីកម្ចាត់សត្វល្អិត ដង្កូវ មេរោគប្រភេទណាមួយ។
- 

**ឧទាហរណ៍៖** កូនឬស្សីព្រៃ៥គីឡូក្រាម (ចិញ្ច្រាំអោយម៉ត់ឬដុំតូចៗ) រួចដាក់ត្រាំទឹកភ្លៀងដើមឆ្នាំ១០លីត្រ ទុករយៈពេល ២សប្តាហ៍។ ពេលប្រើប្រាស់

គឺយកមេថ្នាំទឹក១លីត្រ  លាយទឹក ៣លីត្រ  សម្រាប់បាញ់លើបន្លែតូចៗ

និងយកមេថ្នាំទឹក១លីត្រ  លាយទឹក ១លីត្រ  សម្រាប់បាញ់លើបន្លែធំៗ។

- **រូបមន្តទ្វេ (២មុខ)៖ ជាការជ្រើសរើសយករុក្ខជាតិពីរប្រភេទផ្សេងគ្នាដើម្បីផ្សំជាថ្នាំពុល។**

**ឧទាហរណ៍៖ ស្លឹកទន្រ្ទានខែត្រ ១គីឡូ + បណ្តូលពេជ្រ 0,៥គីឡូ ស្ងោរជាមួយទឹក ៥លីត្រដាំអោយពុះទុកអោយត្រជាក់យកមកធ្វើថ្នាំ។**

- **រូបមន្តចម្រុះ (ច្រើនមុខ)៖** ជាការជ្រើសរើសរុក្ខជាតិថ្នាំពុលច្រើនប្រភេទរួមគ្នា ដើម្បីយកមកចម្រាញ់ធ្វើជាថ្នាំពុលក្នុងការកម្ចាត់សត្វល្អិត ឬ ដង្កូវ ឬមេរោគណាមួយ។

រូបមន្តចម្រុះមានប្រសិទ្ធភាពជាងរូបមន្តទោល និងទ្វេ ដោយហេតុថា សកម្មភាពប្រឆាំងរបស់ថ្នាំមានច្រើនគោលដៅ ដែលធ្វើអោយសត្វល្អិត ឬ មេរោគពិបាកនឹងស៊ូទ្រាំ ដោយសារវាវាយប្រហារលើប្រព័ន្ធប្រសាទ វាយប្រហារលើស្បែក វាយប្រហារលើប្រព័ន្ធដង្ហើម វាយប្រហារលើប្រព័ន្ធរំលាយអាហារ។

# ៣.៧ ការគ្រប់គ្រងទឹក

## ហេតុអ្វីត្រូវគិតគូរអំពីការគ្រប់គ្រងទឹកលើដំណាំ?

គឺដើម្បីរក្សាបានការស្រោចស្រពដំណាំដែលមានលក្ខណៈសន្សំសំចៃទឹក ធានាបានដំណាំលូតលាស់ មានសុខភាពល្អ និងទទួលបានទិន្នផលខ្ពស់។

ការផ្គត់ផ្គង់ទឹកមិនគ្រប់គ្រាន់ ឬលើសពីតម្រូវការធ្វើអោយដំណាំលូតលាស់មិនល្អ កើតមានជំងឺ និងខ្ជះខ្ជាយទឹក។

បច្ចេកទេសមួយចំនួនអាចជួយអោយកសិករប្រើប្រាស់ទឹកមានប្រសិទ្ធភាព សន្សំសំចៃខ្ពស់ និងអាចផ្គត់ផ្គង់គ្រប់រដូវកាល ដូចជា៖

- ការគ្របរងដំណាំដោយប្រើអង្កាមស្រស់ ឬធ្យូងអង្កាម ឬចំបើង



- ការគ្របដីដោយប្លាស្ទិក



- ការស្រោចស្រពដោយតំណក់ទឹក, ការបាញ់សាច, បង្ហូរតាមចង្អូរជាដើម។







# ៣.៨ ការប្រមូលផល

តើត្រូវគិតគូរអ្វីខ្លះមុនពេល អំឡុងពេល និងក្រោយពេលប្រមូលផល?

- មុនពេលប្រមូលផល៖ បញ្ឈប់ការប្រើប្រាស់ថ្នាំពុលយ៉ាងតិច ៧ថ្ងៃ មុនប្រមូលផល និងបញ្ឈប់ការស្រោចទឹក ១ថ្ងៃមុនប្រមូលផល។

- ពេលប្រមូលផល៖ – ប្រមូលផលពេលព្រឹក ឬពេលល្ងាច
  – ការប្រមូលផលបន្លែគ្រប់អាយុ
  – ប្រមូលផលភ្លាម ត្រូវយកទៅរក្សាទុកកន្លែងម្លប់
  – មិនគួរប្រមូលផលក្រោយមេឃភ្លៀងភ្លាមៗឡើយ ឬមាន សន្សើមធ្លាក់ខ្លាំងឡើយ

- ក្រោយប្រមូលផល៖ – ការលាងសំអាត និងជ្រើសរើស



  – ការចាត់ថ្នាក់ (លេខ1 លេខ 2 និងលេខ3) ទៅតាមទំហំ ប្រវែង និង ភាពចាស់ឬទុំ




  – ការវេចខ្ចប់ (មិនធ្ងន់ពេក ស្រួលលើក)



  – ការរក្សាទុកក្នុងបន្ទប់ក្លាសេ/បន្ទប់ត្រជាក់



  – ការដឹកជញ្ជូនដែលសមប្រកបសំរាប់ការរក្សាគុណភាពបន្លែ

